មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេប
# ការមិនលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចំពោះសកម្មជនមាតាធម្មជាតិ ៥ រូប

ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥


## សង្ខេប

មកដល់ពេលនេះ សកម្មជនការពារបរិស្ថានចំនួន ៥ រូប មកពីក្រុមមាតាធម្មជាតិកម្ពុជា រួមមាន កញ្ញា ឡុង គន្ធា លោក យឹម លាងហ៊ី លោក ថុន រដ្ឋា កញ្ញា ភួន កែវរស្មី និង លោក លី ចាន់ដារ៉ាវុត បានរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេអស់រយៈពេលជិតមួយឆ្នាំកន្លះមកហើយ តាំងពីពួកគេត្រូវបានផ្តន្ទាទោសកាលពីខែកក្កដា ឆ្នាំ២០២៤។ ក្នុងអំឡុងពេលជាប់ពន្ធនាគាររងចាំការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ពួកគេមិនត្រឹមតែឃ្លាតឆ្ងាយពីក្រុមគ្រួសារប៉ុណ្ណោះទេ ពួកគេក៏ត្រូវបានបំបែកឱ្យនៅឆ្ងាយពីគ្នានៅតាមពន្ធនាគារផ្សេងៗផងដែរ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បានវាយតម្លៃថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សកម្មជនទាំងនេះ មិនត្រូវបានលើកកម្ពស់ឡើយ។ សិទ្ធិទាំងនោះរួមមាន៖

- **សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ**
- **សិទ្ធិមានសេរីភាព**
- **សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស**


## សាវតារ

សកម្មជនការពារបរិស្ថានទាំងនោះ ត្រូវបានផ្តន្ទាទោសកាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ ពីបទ «រួមគំនិតក្បត់» ចំណែកលោក យឹម លាងហ៊ី ត្រូវបានផ្តន្ទាទោសជាមួយនឹងបទចោទបន្ថែមមួយទៀតគឺបទ «ប្រមាថចំពោះអង្គព្រះមហាក្សត្រ» ហើយអ្នកទាំងអស់នោះត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលពី ៦ ឆ្នាំទៅ ៨ ឆ្នាំ។ សកម្មជនប្រាំនាក់ផ្សេងទៀតត្រូវបានផ្តន្ទាទោសនៅថ្ងៃជាមួយគ្នាដោយមិនមានវត្តមានរបស់ពួកគេ។

សវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេ ត្រូវបានកំណត់ពេលជំនុំជម្រះនៅសាលាឧទ្ធរណ៍ភ្នំពេញ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥។ ទោះជាយ៉ាងណាក៏ដោយ នៅប៉ុន្មានថ្ងៃមុនកាលបរិច្ឆេទសវនាការមកដល់

សាលាឧទ្ធរណ៍ភ្នំពេញបានប្រកាសលើកពេលសវនាការទៅពេលក្រោយវិញ ក្រោមហេតុផលថា មិនអាចបញ្ជូនជីកាកោះដល់ជនជាប់ចោទដែលនៅក្រៅឃុំ។

នៅថ្ងៃទី២៦ ខែធ្នូនេះ គឺមានរយៈពេលប្រាំមួយខែគិតពីពេលសវនាការបណ្តឹងឧទ្ធរណ៍របស់ពួកគេត្រូវបានគ្រោងធ្វើឡើង។ ការពន្យារពេលដ៏យូរនេះ ម.ស.ម.ក ធ្វើការវាយតម្លៃ អំពីផលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេ។ ម.ស.ម.ក បានចាត់ទុកថា ការពន្យារពេលនេះមិនត្រឹមតែប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេប៉ុណ្ណោះទេ ហើយការបដិសេធសំណើសុំនៅក្រៅឃុំម្តងហើយម្តងទៀត ក្នុងអំឡុងពេលពួកគេរង់ចាំសវនាការបណ្តឹងឧទ្ធរណ៍នោះ រឹតតែធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិមានសេរីភាពរបស់ពួកគេបន្ថែមទៀត។

## វិភាគ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានធានាតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២។ ក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នេះ ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។ សិទ្ធិនេះមានធាតុផ្សំជាច្រើន ដែលធាតុទាំងនោះមានភាពពាក់ព័ន្ធគ្នា និងមានឥទ្ធិពលដល់គ្នាទៅវិញទៅមក ដូចជា សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលយូរហួសហេតុ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិមានសេរីភាព។ ម.ស.ម.ក ធ្វើការវិភាគលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗទាំងនេះ ក្នុងសំណុំរឿងនៃសកម្មជនមាតាធម្មជាតិ ដូចខាងក្រោម៖

### សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ

ការពន្លឿននូវនីតិវិធីឱ្យឆាប់រហ័សនៃការជំនុំជម្រះនៅសាលាដំបូង ឬតុលាការជាន់ខ្ពស់ គឺជាមូលដ្ឋានគ្រឹះក្នុងការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌។ កាលណាដំណើរការជំនុំជម្រះកាន់តែអូសបន្លាយពេលយូរ កាន់តែបង្កការលំបាកដល់ដំណើរការនៃជំនុំជម្រះ ដូចជាការប៉ះពាល់ដល់លទ្ធភាពទទួលបានភស្តុតាង (ឧទាហរណ៍ ការបាត់បង់ ការខូចគុណភាព ឬការបំផ្លាញភស្តុតាង) ហើយសក្ខីកម្មរបស់សាក្សី ឬវត្តមានរបស់ពួកគេក៏អាចរងផលប៉ះពាល់ដោយសារពេលវេលាកន្លងទៅយូរ។ ការរំលោភបំពានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល បង្កឱ្យមានការរំខានដល់ដំណើរការជំនុំជម្រះលើបុគ្គលណាម្នាក់ អាចនាំឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សតិអារម្មណ៍ ពីការបន្តនូវការចោទប្រកាន់នេះ និងសិទ្ធិនេះបានកំណត់ផងដែរថាបុគ្គលដែលរងការចោទប្រកាន់ត្រូវចាត់ទុកជាមនុស្សគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញដោយតុលាការ ដែលសេចក្តីសម្រេចនោះបានចូលជាស្ថាពរ ម្យ៉ាងទៀតបន្ទុកនៃការបង្ហាញពីពិរុទ្ធភាព/ភស្តុតាងជាកាតព្វកិច្ចរបស់ភាគី

តំណាងអយ្យការ។[1] សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល មិនត្រឹមតែធ្វើឡើងដើម្បីផលប្រយោជន៍ល្អបំផុតសម្រាប់ជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីបម្រើប្រយោជន៍ដល់យុត្តិធម៌ផងដែរ។[2]

ពុំមានការកំណត់ជាក់លាក់ណាមួយពីថិរវេលា ថាអ្វីទៅជាការពន្យារពេលក្នុងរយៈពេលសមរម្យ ឬហួសហេតុ នោះទេ។ ភាពសមរម្យនៃពេលវេលាដែលត្រូវប្រើប្រាស់ ដើម្បីនាំខ្លួនបុគ្គលដែលកំពុងជាប់ឃុំមកជំនុំជម្រះ ឬរាល់ការបង្អង់ណាមួយក្នុងនីតិវិធីព្រហ្មទណ្ឌ ត្រូវតែធ្វើការវាយតម្លៃទៅតាមករណីនីមួយៗ ដោយផ្អែកលើការពិនិត្យទៅលើកាលៈទេសៈនៃរឿងក្តីនីមួយៗ រួមមានភាពស្មុគស្មាញនៃរឿងក្តី (ឧទាហរណ៍ ចំនួនមនុស្សជាប់ពាក់ព័ន្ធក្នុងបទល្មើស ចំនួនបទចោទ និងប្រភេទនៃការស៊ើបអង្កេតដែលត្រូវធ្វើជាដើម)។[3]

មកដល់ពេលនេះ សកម្មជនមាតាធម្មជាតិបានរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេអស់រយៈពេលជិតមួយឆ្នាំកន្លះមកហើយ។ យោងតាមវិធីសាស្ត្រសង្កេតសវនាការរបស់ ម.ស.ម.ក សិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យារពេល ត្រូវបានចាត់ទុកថាត្រូវបានគោរព ប្រសិនបើការសវនាការបានប្រព្រឹត្តទៅក្នុងរយៈពេលមិនលើសប្រាំមួយខែ បន្ទាប់ពីសាលាឧទ្ធរណ៍បានទទួលពាក្យបណ្តឹងឧទ្ធរណ៍[4]។ តាមរយៈបទដ្ឋាននេះ និងដោយពិនិត្យឃើញថា កាលបរិច្ឆេទសម្រាប់សវនាការបណ្តឹងឧទ្ធរណ៍ ដែលគ្រោងធ្វើឡើងក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីការផ្តន្ទាទោសពួកគេ ត្រូវបានពន្យារពេលអស់រយៈពេលប្រាំមួយខែបន្ថែមទៀតនោះ ម.ស.ម.ក វាយតម្លៃថា សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលរបស់សកម្មជនមាតាធម្មជាតិ មិនត្រូវបានគោរពឡើយ។

## សិទ្ធិមានសេរីភាព

សិទ្ធិទទួលបានសេរីភាពត្រូវបានធានាដោយមាត្រា ៩ នៃ ក.អ.ស.ព.ន ដែលចែងថា «ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឬការឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់»។ សូមបញ្ជាក់ផងដែរថា យោងតាមច្បាប់អន្តរជាតិ ការឃុំខ្លួនជនណាម្នាក់អាចត្រូវបានចាត់ទុកថាជាការឃុំខ្លួនតាមអំពើចិត្ត ប្រសិនបើការបង្គាប់

---

[1] ម.ស.ម.ក, មេរៀន៖ សិទ្ធិមានសេរីភាព, សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល (ខែកញ្ញា ឆ្នាំ២០២២)

[2] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទូលេខ៣២ កថាខណ្ឌទី៣៥

[3] ដូចខាងលើ, កថាខណ្ឌទី៣៦ គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់លេខ៣៥, កថាខណ្ឌទី៣៧

[4] ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា (ថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤), ទំព័រទី៣៧

ឱ្យឃុំខ្លួននោះធ្វើឡើងចំពោះការអនុវត្តសិទ្ធិមូលដ្ឋានរបស់ពួកគេ ក្នុងនោះមានការអនុវត្តនូវសេរីភាពខាងការបញ្ចេញមតិផងដែរ ហើយដែលករណីនេះហាក់កំពុងកើតឡើងទៅលើសកម្មជនមាតាធម្មជាតិ។[5]

ពាក់ព័ន្ធនឹងការនៅក្រៅឃុំជាបណ្ដោះអាសន្ន និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានចែងថា «នៅក្នុងករណីនានា ដែលជនជាប់ចោទត្រូវបានតុលាការបដិសេធមិនឱ្យនៅក្រៅឃុំដោយការដាក់ប្រាក់ធានា ពួកគេត្រូវតែទទួលបានការជំនុំជម្រះយ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ ការធានាការពារនេះ ពាក់ព័ន្ធនឹង មិនត្រឹមតែពេលវេលារវាងការចោទប្រកាន់ជនជាប់ចោទជាផ្លូវការ និងពេលវេលាដែលជំនុំជម្រះត្រូវចាប់ផ្ដើមនោះទេ ប៉ុន្តែក៏ត្រូវពាក់ព័ន្ធនឹងពេលវេលារហូតដល់មានសាលដីកាស្ថាពរផងដែរ។ នៅគ្រប់ដំណាក់កាល ទោះជានៅសាលាដំបូង ឬនៅសាលាឧទ្ធរណ៍ត្រូវតែប្រព្រឹត្តទៅ ដោយ "គ្មានការពន្យាពេលមិនត្រឹមត្រូវ"ឡើយ។[6]

ចាប់តាំងពីការចាប់ខ្លួនដែលបានធ្វើឡើងជាមួយនឹងការប្រើប្រាស់កងកម្លាំងដោយមិនចាំបាច់មក សំណើសុំនៅក្រៅឃុំរបស់ កញ្ញា ឡុង គន្ធា លោក យីម លាងហ៊ី លោក ថុន រដ្ឋា កញ្ញា ភួន កែវរស្មី និង លោក លី ចាន់ដារ៉ាវុត ត្រូវបានបដិសេធចំនួន ៣ លើករួចមកហើយ ដោយលើកទីមួយសាលាឧទ្ធរណ៍ភ្នំពេញក្នុងខែកុម្ភៈ ឆ្នាំ២០២៥ លើកទីពីរនៅតុលាការកំពូលក្នុងខែមេសា ឆ្នាំ២០២៥ និងលើកទីបីត្រូវបានសាលាឧទ្ធរណ៍ភ្នំពេញបដិសេធម្តងទៀតក្នុងខែធ្នូ ឆ្នាំ២០២៥ ។ ការពន្យារពេលសវនាការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ រួមផ្សំនឹងការបដិសេធសំណើសុំនៅក្រៅឃុំម្ដងហើយម្ដងទៀត បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមានសេរីភាពរបស់ពួកគេ។

## សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស គឺជាគោលការណ៍ដ៏សំខាន់មួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើម្បីធានានូវការផ្តល់យុត្តិធម៌។ ការសន្មតទុកជាមុនថាគ្មានទោសត្រូវអនុវត្តនៅក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌរាប់ចាប់តាំងពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ និងនីតិវិធីនៃការជំនុំជម្រះ រហូតដល់ការបញ្ចប់ដំណាក់កាលចុងក្រោយនៃនីតិវិធីបណ្តឹងតវ៉ាត្រូវ

---

[5] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្ត, សាលាកប័ត្រលេខ២៦, ទំព័រទី១១-២០ https://tinyurl.com/UN-WGAD
ក្រុមប្រឹក្សាសិទ្ធិមនុស្ស, ក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្តរបស់អង្គការសហប្រជាជាតិ - សេចក្តីសម្រេចលេខ០៥/២០២៣ ពាក់ព័ន្ធនឹង សេង ចាន់ធារី (កម្ពុជា) កថាខណ្ឌទី ៥៦-៧១, ៨៦ https://tinyurl.com/293bw6ua
ក្រុមប្រឹក្សាសិទ្ធិមនុស្ស, ក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្តរបស់អង្គការសហប្រជាជាតិ - សេចក្តីសម្រេចលេខ៧៥/២០២១ ពាក់ព័ន្ធនឹង រស់ សុឃិត (កម្ពុជា) កថាខណ្ឌទី ៥៣-៦១, ៨១ https://tinyurl.com/3an5dhmv

[6] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ កថាខណ្ឌទី៣៥

បានបញ្ចប់[7]។ កាលណាការជំនុំជម្រះកាន់តែអូសបន្លាយពេលកាន់តែយូរ ហានិភ័យពីការរំលោភសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសលើជនដែលរងការចោទត្រូវបានប៉ះពាល់កាន់តែខ្លាំង ដោយហេតុថាការចោទប្រកាន់នេះត្រូវបានបន្តកាន់តែយូរដោយមិនមានការបញ្ជាក់ឱ្យច្បាស់លាស់។ សិទ្ធិនេះក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិមានសេរីភាពផងដែរ កាលបើជនដែលរងការចោទប្រកាន់បន្តឃុំខ្លួនកាន់តែយូរ ទោះបីនៅដំណាក់កាលឃុំខ្លួនបណ្ដោះអាសន្ន ឬដំណាក់កាលរង់ចាំការជំនុំជម្រះនៅសាលាឧទ្ធរណ៍ ក៏សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរងនូវការរំលោភបំពានកាន់តែខ្ពស់។[8]

រហូតដល់ពេលនេះសកម្មជនមាតាធម្មជាតិបានជាប់ពន្ធនាគារជិត ១៨ ខែមកហើយដោយរង់ចាំការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ពួកគេ ខណៈដែលសំណើសុំនៅក្រៅឃុំរបស់ពួកគេត្រូវបដិសេធជាបន្តបន្ទាប់ ទាំងនេះនាំឱ្យរំលោភបំពានលើសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ ការបង្ហាញខ្លួននៅចំពោះមុខតុលាការ អ្នកការពារបរិស្ថានទាំងប្រាំរូបតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ទឹកក្រូចចាស់ ដែលជាឯកសណ្ឋានសម្រាប់ជនជាប់ឃុំដែលមិនទាន់មានសាលក្រម ឬសាលដីកាចូលជាស្ថាពរ។ ដូចដែល ម.ស.ម.ក បានលើកឡើងកន្លងមកថា ជនជាប់ចោទគួរតែត្រូវបានអនុញ្ញាតឱ្យសម្លៀកបំពាក់ស៊ីវិលផ្ទាល់ខ្លួនរបស់ពួកគេក្នុងពេលសវនាការ ដែលបង្ហាញពីសេចក្ដីថ្លៃថ្នូរ និងស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។[9]

## សេចក្ដីសន្និដ្ឋាន

ដូចដែលការវិភាគនេះបានបង្ហាញ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់កញ្ញា ឡុង គន្ធា លោក យីម លាងហ៊ី លោក ថុន រដ្ឋា កញ្ញា ភួន កែវរស្មី និង លោក លី ចាន់ដារ៉ាវុត ត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលមួយឆ្នាំកន្លះកន្លងមកនេះ។ ការពន្យារពេលសវនាការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ និងការបដិសេធសំណើសុំនៅក្រៅឃុំម្ដងហើយម្ដងទៀតដោយតុលាការ មិនត្រឹមតែជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល និងសិទ្ធិមានសេរីភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេផងដែរ។ ទាំងនេះ ជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ក្នុងនាមជារដ្ឋភាគីដែលបានផ្ដល់សច្ចាប័នលើ ក.អ.ស.ព.ន ប្រទេសកម្ពុជាមានកាតព្វកិច្ច និងធានាថាសកម្មជនមាតាធម្មជាតិត្រូវទទួលបាននូវការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ពួកគេក្នុងពេលវេលាឆាប់រហ័សដែលអាចធ្វើទៅបាន។ ម.ស.ម.ក ក៏សូមស្នើឡើងជាថ្មីម្ដងទៀតឱ្យលុបចោលការផ្ដន្ទាទោសលើអ្នកការពារបរិស្ថានទាំងប្រាំរូប និងដោះលែងពួកគេជាបន្ទាន់ដោយគ្មានលក្ខខណ្ឌ។

---

[7] ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ‵សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី១), ជំពូកទី៦′, ទំព័រទី២១៩ https://tinyurl.com/35w2rrm6

[8] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្ដីពន្យល់ទូទៅលេខ ៣៥ កថាខណ្ឌទី៣៧

[9] ម.ស.ម.ក, សេចក្ដីវិភាគអំពីការជំនុំជម្រះដោយយុត្តិធម៌ - ឯកសណ្ឋានពន្ធនាគារ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ https://tinyurl.com/49mcw9dz

សម្រាប់ព័ត៌មានបន្ថែម សូមអ៊ីម៉ែលទៅកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org ឬទូរស័ព្ទមកកាន់ +៨៥៥ ២៣ ៧២ ៦៩ ០១

**ខែធ្នូ ឆ្នាំ២០២៥**

CC BY NC SA